# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)

## របាយការណ៍ប្រចាំសប្តាហ៍ លេខ៤

សំណុំរឿង០០២ វគ្គ១ បានមកដល់ទីបញ្ចប់ក្នុងសប្តាហ៍នេះ ដោយអង្គជំនុំជម្រះតុលាការកំពូលបានប្រកាសពីសាលដីការបស់ខ្លួន[1] លើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងកាលពីខែសីហា ឆ្នាំ២០១៤ កន្លងទៅ។[2] ឯកឧត្តមប្រធានអង្គជំនុំជម្រះតុលាការកំពូល **គង់ ស្រីម** បានអានសេចក្តីសង្ខេបនៃសេចក្តីសម្រេចនេះ ដោយបានគូសបញ្ជាក់ពី "ភាពចម្រូងចម្រាស់បំផុត" នៃទឡ្ហីករណ៍សរុបរួមគ្នារបស់ក្រុមមេធាវីការពារក្តីមានចំនួន ៣៧១ ក្នុងបណ្តឹងសាទុក្ខ ក៏ដូចជា ទឡ្ហីករណ៍ក្នុងបណ្តឹងសាទុក្ខរបស់ការិយាល័យសហព្រះរាជអាជ្ញាផងដែរ ពាក់ព័ន្ធនឹងការអនុវត្តទម្រង់ពង្រីកបន្ថែមនៃសហឧក្រិដ្ឋកម្មរួម ជាទូទៅហៅថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ (JCE III)។ ថ្វីបើអង្គជំនុំជម្រះតុលាការកំពូលបានបដិសេធនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង រួមមាន ការលើកលែងការចោទប្រកាន់សហជនជាប់ចោទពីការទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ នៅចុងខែមេសា ឆ្នាំ១៩៧៥ ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលជាចម្បងនៅរក្សាទោសដាក់គុកមួយជីវិតចំពោះជនជាប់ចោទម្នាក់ៗ ដោយលើកឡើងថា ប្រការរកឃើញនេះ ឆ្លុះបញ្ចាំងភាគច្រើនបំផុតជាស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលជនជាប់ចោទពីរត្រូវបានចោទប្រកាន់។ របាយការណ៍នេះ

---

[1] អង្គជំនុំជម្រះតុលាការកំពូល "សាលដីកាលើបណ្តឹងសាទុក្ខលើសំណុំរឿង០០២ វគ្គ១" ចុះថ្ងៃទី២៣ ខែវិច្ឆិកា ២០១៦ ឯកសារលេខ F36 [ចាប់ពីពេលនេះហៅថា សាលដីកាលើបណ្តឹងសាទុក្ខ]។

[2] អង្គជំនុំជម្រះសាលាដំបូង "សាលក្រមលើសំណុំរឿង០០២ វគ្គ១" (ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤)ឯកសារលេខ E313 [ចាប់ពីពេលនេះហៅថា សាលក្រមបណ្តឹងសាទុក្ខ]។

រៀបរាប់ពីព័ត៌មានគ្រួសៗមួយចំនួន ស្ដីពីសេចក្ដីសម្រេចក្នុងសប្ដាហ៍នេះ ដោយសង្ខេបពីការរកឃើញសំខាន់ៗ ដែលបានប្រកាសដោយឯកឧត្ដមប្រធានអង្គជំនុំជម្រះ នៅថ្ងៃពុធ នេះ។ ការវិភាគលម្អិត និងស៊ីជម្រៅនៃសេចក្ដីសម្រេចនេះនឹងត្រូវផ្សព្វផ្សាយ នៅក្រោយពេលដែលអ្នកឃ្លាំមើលសវនាការមានពេលវេលាគ្រប់គ្រាន់ ដើម្បីអាន និងស្វែងរកយល់ពីសាលដីកាដែលមានកម្រាស់ ៥២០ ទំព័រនេះ។

---

* របាយការណ៍នេះ ត្រូវបានសរសេរដោយ ខេតលីន កាហ្វហ្វ្រៀ (Caitlin McCaffrie) និង ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្ដួចផ្ដើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី(AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (WSD Handa Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្ដួចផ្ដើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University